| ឯកសារស្តីពីព័ត៌មានរបស់ផលិតផល | ក្រុមហ៊ុន ព្រូដិនសល (ខេមបូឌា) ឡាយហ្វ៍អឹស្សួរិនស៍ |
|---|---|
| *(សូមអានឯកសារស្តីពីព័ត៌មានរបស់ផលិតផលនេះ និង អាន ខ និងលក្ខខណ្ឌនៅក្នុងឯកសារបណ្ណសន្យារ៉ាប់រង)* | ***PRUថែទាំ*** *ជាផលិតផលដែលមានលក្ខណៈជាការធានារ៉ាប់រងមានកាលកំណត់សម្រាប់ផ្តល់ជូនអត្ថប្រយោជន៍ធានារ៉ាប់រងក្នុងរយៈពេលកំណត់នៃបណ្ណសន្យារ៉ាប់រងដោយម្ចាស់បណ្ណសន្យារ៉ាប់រងនឹងមិនទទួលបានការប្រាក់ភាគលាភ និង ផលចំណេញផ្សេងៗ ដែលបានមកពីការវិនិយោគទៅលើបុព្វលាភធានារ៉ាប់រងដែលបានបង់នោះឡើយ (Non-Participating) និងផ្តល់ការការពារក្នុងករណីមរណភាព ឬ ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ រួមជាមួយផលិតផលធានារ៉ាប់រងបន្ថែម* ***PRUការពារជំងឺធ្ងន់ធ្ងរ*** *ដែលផ្តល់ការការពារលើផ្នែកហិរញ្ញវត្ថុទៅលើលក្ខខណ្ឌវេជ្ជសាស្ត្រដែលបានផ្តល់ជូន។* |

## 1. អ្វីទៅជា PRUថែទាំ?

**PRUថែទាំ** ជាផលិតផលធានារ៉ាប់រងអាយុជីវិតដែលមានលក្ខណៈជាការធានារ៉ាប់រងមានកាលកំណត់សម្រាប់ផ្តល់ជូនអត្ថប្រយោជន៍ធានារ៉ាប់រងក្នុងរយៈពេលកំណត់នៃបណ្ណសន្យារ៉ាប់រងដែលផ្តល់ការការពារផ្នែកហិរញ្ញវត្ថុក្នុងករណីមរណភាព ឬ ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ និងផ្តល់ការការពារផ្នែកហិរញ្ញវត្ថុក្នុងករណីមរណភាព ឬ ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍។ ផលិតផលធានារ៉ាប់រងបន្ថែមដែលអាចទិញភ្ជាប់ទៅនឹងផលិតផលនេះគឺផលិតផលធានារ៉ាប់រងបន្ថែម **PRUការពារជំងឺធ្ងន់ធ្ងរ** ដែលផ្តល់ការការពារផ្នែកហិរញ្ញវត្ថុលើលក្ខខណ្ឌវេជ្ជសាស្ត្រដែលបានផ្តល់ជូនរួមមាន ករណីជំងឺធ្ងន់ធ្ងរ ជំងឺធ្ងន់ធ្ងរកើតឡើងលើកុមារ អត្ថប្រយោជន៍បន្ថែមលើជំងឺមហារីក (តាមភេទ) ផលវិបាកនៃការមានគភ៌ ការវះកាត់ស្តារឡើងវិញ ឬការផ្សាំនៃស្បែក និងផលវិបាកនៃជំងឺទឹកនោមផ្អែម។

លក្ខណៈសម្បត្តិរបស់ផលិតផល **PRUថែទាំ** និងផលិតផលធានារ៉ាប់រងបន្ថែម **PRUការពារជំងឺធ្ងន់ធ្ងរ** មានបង្ហាញដូចខាងក្រោម៖

| ប្រភេទនៃផលិតផល | ការការពារ |
|---|---|
| អត្ថប្រយោជន៍ផ្តល់ជូនសម្រាប់អតិថិជនរួមមាន៖ | - អត្ថប្រយោជន៍ក្នុងករណីមរណភាព ឬ ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍<br>- អត្ថប្រយោជន៍ក្នុងករណីជំងឺធ្ងន់ធ្ងរ (រួមបញ្ចូលអត្ថប្រយោជន៍នៃការលើកលែងបុព្វលាភធានារ៉ាប់រង)<br>- អត្ថប្រយោជន៍ក្នុងករណីជំងឺធ្ងន់ធ្ងរកើតឡើងលើកុមារ (រួមបញ្ចូលអត្ថប្រយោជន៍នៃការលើកលែងបុព្វលាភធានារ៉ាប់រង)<br>- អត្ថប្រយោជន៍បន្ថែមលើជំងឺមហារីក (តាមភេទ)<br>- អត្ថប្រយោជន៍សម្រាប់ផលវិបាកនៃការមានគភ៌<br>- អត្ថប្រយោជន៍សម្រាប់ការវះកាត់ស្តារឡើងវិញ ឬការផ្សាំនៃស្បែក |

| | |
|---|---|
| | - អត្ថប្រយោជន៍សម្រាប់ផលវិបាកនៃជំងឺទឹកនោមផ្អែម |
| ទឹកប្រាក់ត្រូវបានធានារ៉ាប់រង | - អប្បបរមា 1000 ដុល្លារអាមេរិក (USD)<br>- អតិបរមា 5000 ដុល្លារអាមេរិក (USD) |
| រយៈពេលកំណត់នៃការបង់បុព្វលាភធានារ៉ាប់រង /រយៈពេលកំណត់នៃបណ្ណសន្យារ៉ាប់រង | 5 ឆ្នាំ |
| របៀបនៃការបង់បុព្វលាភធានារ៉ាប់រង | - បុព្វលាភធានារ៉ាប់រងត្រូវទូទាត់ជាទៀងទាត់ (ប្រចាំឆ្នាំ ប្រចាំឆមាស ប្រចាំត្រីមាស និងប្រចាំខែ)<br>- បុព្វលាភធានារ៉ាប់រងដែលត្រូវបង់មានតម្លៃថេរ ក្នុងអំឡុងរយៈពេលកំណត់នៃបណ្ណសន្យារ៉ាប់រង |
| រូបិយបណ្ណ | ដុល្លារអាមេរិក (USD) |

- **អាយុចាប់ផ្តើមរបស់អ្នកត្រូវបានធានារ៉ាប់រង៖**
    - អត្ថប្រយោជន៍ក្នុងករណីធ្ងន់ធ្ងរជំងឺកើតឡើងលើកុមារ៖ អាយុចាប់ពី 1 ឆ្នាំ ដល់ 14 ឆ្នាំ
    - អត្ថប្រយោជន៍សម្រាប់ផលវិបាកនៃការមានគភ៌៖ អាយុចាប់ពី 18ឆ្នាំ ដល់ 39ឆ្នាំ
    - អត្ថប្រយោជន៍សម្រាប់ការវះកាត់ស្តារឡើងវិញ ឬការផ្សាំនៃស្បែក ៖ អាយុចាប់ពី 18ឆ្នាំ ដល់ 60ឆ្នាំ
    - អត្ថប្រយោជន៍ផ្សេងៗទៀត៖ អាយុចាប់ពី 18ឆ្នាំ ដល់ 60ឆ្នាំ
- **អាយុផុតសុពលភាពធានារ៉ាប់រងរបស់អ្នកត្រូវបានធានារ៉ាប់រង៖**
    - អត្ថប្រយោជន៍ក្នុងករណីជំងឺធ្ងន់ធ្ងរកើតឡើងលើកុមារ៖ អាយុ 18 ឆ្នាំ
    - អត្ថប្រយោជន៍សម្រាប់ផលវិបាកនៃការមានគភ៌៖ អាយុ 44ឆ្នាំ
    - អត្ថប្រយោជន៍ផ្សេងៗទៀត៖ អាយុ 70ឆ្នាំ

**2. តើអត្ថប្រយោជន៍របស់ផលិតផល PRUថែទាំ និង ផលិតផលធានារ៉ាប់រងបន្ថែម PRUការពារជំងឺធ្ងន់ធ្ងរ មានអ្វីខ្លះ?**

ប្រសិនបើអត្ថប្រយោជន៍ណាមួយខាងក្រោមនេះត្រូវបានជ្រើសរើស នោះវានឹងត្រូវបានទូទាត់ជូនដូចខាងក្រោម៖

| អត្ថប្រយោជន៍ | អត្ថប្រយោជន៍ទទួលបាន |
|---|---|
| អត្ថប្រយោជន៍ក្នុងករណីមរណភាព ឬករណីពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ | 100% នៃទឹកប្រាក់ត្រូវបានធានារ៉ាប់រងនឹងត្រូវបានទូទាត់ជូនក្នុងករណីមរណភាព ឬករណីពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ |
| ជំងឺធ្ងន់ធ្ងរ<br>(Critical Illness) | អត្ថប្រយោជន៍បន្ថែមទទួលបានស្មើនឹង 500% នៃទឹកប្រាក់ត្រូវបានធានារ៉ាប់រង ក្នុងករណីធ្វើរោគវិនិច្ឆ័យរកឃើញថាមានជំងឺធ្ងន់ធ្ងរណាមួយដូចដែលបានកំណត់ចំនួន 5 ករណី។ បុព្វលាភធានារ៉ាប់រងនាពេលអនាគតរបស់អត្ថប្រយោជន៍ផ្សេងទៀតនឹងត្រូវបានលើកលែង ក្នុងករណីមាន |

| | |
|---|---|
| | ការទាមទារសំណងសម្រាប់អត្ថប្រយោជន៍នេះបានជោគជ័យ។ |
| ជំងឺធ្ងន់ធ្ងរកើតឡើងលើកុមារ<br>(Juvenile Medical Conditions) | អត្ថប្រយោជន៍បន្ថែមទទួលបានស្មើនឹង 500% នៃទឹកប្រាក់ត្រូវបានធានារ៉ាប់រង ក្នុងករណីធ្វើរោគវិនិច្ឆ័យរកឃើញថាមានជំងឺធ្ងន់ធ្ងរកើតឡើងលើកុមារណាមួយដូចដែលបានកំណត់ចំនួន 10ករណី។ បុព្វលាភធានារ៉ាប់រងនាពេលអនាគតរបស់អត្ថប្រយោជន៍ផ្សេងទៀតនឹងត្រូវបានលើកលែង ក្នុងករណីមានការទាមទារសំណងសម្រាប់អត្ថប្រយោជន៍នេះបានជោគជ័យ។ |
| អត្ថប្រយោជន៍បន្ថែមលើជំងឺមហារីក (តាមភេទ)<br>(Extra Gender Specific Cancer) | អត្ថប្រយោជន៍បន្ថែមទទួលបានស្មើនឹង 100% នៃទឹកប្រាក់ត្រូវបានធានារ៉ាប់រង ក្នុងករណីធ្វើរោគវិនិច្ឆ័យរកឃើញថាមានជំងឺមហារីកណាមួយដូចដែលបានរាយខាងក្រោម៖<br>- **ចំពោះស្ត្រី:** មហារីកសុដន់ មហារីកមាត់ស្បូន និងមហារីកស្បូន<br>- **ចំពោះបុរស:** មហារីកក្រពេញប្រូស្តាត មហារីកពងស្វាស និងមហារីកលិង្គ<br>អត្ថប្រយោជន៍នេះជាអត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែមលើអត្ថប្រយោជន៍ជំងឺធ្ងន់ធ្ងរ។ |
| ផលវិបាកនៃការមានគភ៌<br>(Pregnancy Complications) | អត្ថប្រយោជន៍បន្ថែមទទួលបានស្មើនឹង 50% នៃទឹកប្រាក់ត្រូវបានធានារ៉ាប់រង ក្នុងករណីធ្វើរោគវិនិច្ឆ័យរកឃើញថាមានស្ថានភាពណាមួយដូចដែលបានកំណត់ចំពោះអត្ថប្រយោជន៍ផលវិបាកនៃការមានគភ៌។ |
| ការវះកាត់ស្តារឡើងវិញ ឬការផ្សាំនៃស្បែក<br>(Reconstructive Surgery or Skin Grafting) | អត្ថប្រយោជន៍បន្ថែមទទួលបានស្មើនឹង 10% នៃទឹកប្រាក់ត្រូវបានធានារ៉ាប់រងក្នុងករណីការវះកាត់ស្តារឡើងវិញដោយសារគ្រោះថ្នាក់ ឬការផ្សាំស្បែកដោយសារការរលាកធ្ងន់ធ្ងរ។<br><br>(*) អនុញ្ញាតឲ្យជាវសម្រាប់តែក្រុមមុខរបរ 1 និង 2 តែប៉ុណ្ណោះ និងមិនអនុញ្ញាតឲ្យជាវសម្រាប់តែក្រុមមុខរបរ 3 និង 4។<br><br>អត្ថប្រយោជន៍នេះត្រូវបានផ្តល់ជូនតែម្តងគត់ ក្នុងមួយករណីគ្រោះថ្នាក់ចៃដន្យឬករណីរលាកធ្ងន់ធ្ងរ និងតែម្តងគត់ក្នុងមួយឆ្នាំបណ្ណសន្យារ៉ាប់រង។ អត្ថប្រយោជន៍នេះអាចធ្វើការទាមទារសំណងរហូតដល់ 3 ដង ដែលការទាមទារសំណងនីមួយៗត្រូវស្ថិតក្នុងឆ្នាំបណ្ណសន្យារ៉ាប់រងខុសគ្នា និង កើតឡើងដោយសារករណីគ្រោះថ្នាក់ចៃដន្យឬករណីរលាក |

| | |
|---|---|
| | ធ្ងន់ធ្ងរផ្សេងគ្នា។ អត្ថប្រយោជន៍នេះនឹងត្រូវបានបញ្ចប់ក្នុងករណីដែលមានការបញ្ចប់កិច្ចសន្យាធានារ៉ាប់រង ឬ ការទាមទារសំណងលើកទី 3 សម្រាប់អត្ថប្រយោជន៍នេះត្រូវបានផ្តលជូន។ |
| ផលវិបាកនៃជំងឺទឹកនោមផ្អែម (Diabetic Complications) | អត្ថប្រយោជន៍បន្ថែមទទួលបានស្មើនឹង 25% នៃទឹកប្រាក់ត្រូវបានធានារ៉ាប់រង ក្នុងករណីអ្នកត្រូវបានធានារ៉ាប់រងត្រូវឆ្លងកាត់ការព្យាបាល និងត្រូវបានធ្វើរោគវិនិច្ឆ័យថាមានស្ថានភាពណាមួយដូចដែលបានកំណត់ចំពោះអត្ថប្រយោជន៍ផលវិបាកនៃជំងឺទឹកនោមផ្អែម។ |

**កំណត់សម្គាល់៖**

- អត្ថប្រយោជន៍ក្នុងករណីជំងឺធ្ងន់ធ្ងរ ជាអត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែមដែលត្រូវជាវជាចាំបាច់។ អត្ថប្រយោជន៍បន្ថែមផ្សេងៗទៀតជាអត្ថប្រយោជន៍បន្ថែមដែលមិនចាំបាច់ជាវជាចាំបាច់ ហើយអតិថិជនអាចជ្រើសរើសបន្ថែម ឬដកចេញ នៅពេលចាប់ផ្តើមជាវបណ្ណសន្យារ៉ាប់រង ឬ នៅពេលបន្តសុពលភាពបណ្ណសន្យាធានារ៉ាប់រង។
- អត្ថប្រយោជន៍នៃផលិតផលធានារ៉ាប់រងបន្ថែមដែលបង្ហាញដូចខាងក្រោមនេះ នឹងត្រូវបានបញ្ចប់ និងមិនអនុញ្ញាតសម្រាប់ការបន្តសុពលភាពបណ្ណសន្យារ៉ាប់រងនោះទេ ប្រសិនបើសំណងត្រូវបានទូទាត់ជូនម្តងរួចរាល់សម្រាប់អត្ថប្រយោជន៍នោះ ៖
    - អត្ថប្រយោជន៍ក្នុងករណីជំងឺធ្ងន់ធ្ងរ
    - អត្ថប្រយោជន៍ក្នុងករណីជំងឺធ្ងន់ធ្ងរកើតឡើងលើកុមារ
    - អត្ថប្រយោជន៍បន្ថែមលើជំងឺមហារីក (តាមភេទ)
    - អត្ថប្រយោជន៍សម្រាប់ផលវិបាកនៃជំងឺទឹកនោមផ្អែម
    - អត្ថប្រយោជន៍សម្រាប់ផលវិបាកនៃការមានគភ៌
- បន្ទាប់ពីមានការបញ្ចប់នៃអត្ថប្រយោជន៍ផលិតផលធានារ៉ាប់រងបន្ថែមដែលបានបង្ហាញដូចក្រោមនេះនៅក្នុងអំឡុងរយៈពេលកំណត់នៃបណ្ណសន្យារ៉ាប់រង នោះបុព្វលាភធានារ៉ាប់រងនៃអត្ថប្រយោជន៍ដែលបានបញ្ចប់នោះនឹងមិនតម្រូវឲ្យទូទាត់ក្នុងអំឡុងរយៈពេលកំណត់នៃបណ្ណសន្យារ៉ាប់រងដែលនៅសល់នោះទេ៖
    - អត្ថប្រយោជន៍សម្រាប់ផលវិបាកនៃជំងឺទឹកនោមផ្អែម
    - អត្ថប្រយោជន៍សម្រាប់ផលវិបាកនៃការមានគភ៌
    - អត្ថប្រយោជន៍សម្រាប់ការវះកាត់ស្តារឡើងវិញ ឬការផ្សាំនៃស្បែក
- បន្ទាប់ពីមានការបញ្ចប់នៃអត្ថប្រយោជន៍ផលិតផលធានារ៉ាប់រងបន្ថែមដែលបានបង្ហាញដូចក្រោមនេះនៅក្នុងអំឡុងរយៈពេលកំណត់នៃបណ្ណសន្យារ៉ាប់រង នោះបុព្វលាភធានារ៉ាប់រងនៃអត្ថប្រយោជន៍ដែលនៅសល់នៃផលិតផលធានារ៉ាប់រងនិងអត្ថប្រយោជន៍នៃផលិតផលធានារ៉ាប់រងបន្ថែមផ្សេងទៀត (បើមាន) នឹងត្រូវបានលើកលែងនៅក្នុងអំឡុងរយៈពេលកំណត់នៃបណ្ណសន្យារ៉ាប់រងដែលនៅសល់នោះ៖
    - អត្ថប្រយោជន៍ក្នុងករណីជំងឺធ្ងន់ធ្ងរ
    - អត្ថប្រយោជន៍ក្នុងករណីជំងឺធ្ងន់ធ្ងរកើតឡើងលើកុមារ
    - អត្ថប្រយោជន៍បន្ថែមលើជំងឺមហារីក (តាមភេទ)

- **ជំងឺធ្ងន់ធ្ងរ៖** ជំងឺមហារីកដំណាក់កាលធ្ងន់ធ្ងរ ជំងឺគាំងបេះដូងដែលមានកម្រិតធ្ងន់ធ្ងរជាក់លាក់ គ្រោះថ្នាក់សរសៃឈាមខួរក្បាលជាមួយការខូចប្រព័ន្ធប្រសាទជាអចិន្ត្រៃយ៍ ជំងឺសរសៃឈាមអាកទែរចិញ្ចឹមបេះដូង និងដុំខួរក្បាលស្លូត។ សូមអានឯកសារបណ្ណសន្យារ៉ាប់រងសម្រាប់និយមន័យ និង ករណីមិនធានា ចំពោះករណីនីមួយៗ។
- **ជំងឺធ្ងន់ធ្ងរកើតឡើងលើកុមារ៖** ជំងឺមហារីកឈាមស ជំងឺទឹកនោមផ្អែមពឹងផ្អែកលើអាំងស៊ុយលីន(ជំងឺទឹកនោមផ្អែមប្រភេទ I) គ្រុនរលាកសន្លាក់ដែលបណ្តាលអោយមានជំងឺប្រើសបេះដូង ជំងឺ Kawasaki ជាមួយនឹងផលវិបាកទៅលើបេះដូង ជំងឺរលាកសន្លាក់រ៉ាំរ៉ៃធ្ងន់ធ្ងរលើកុមារ ការវះកាត់ខួរក្បាល ជំងឺហឺតធ្ងន់ធ្ងរ ជំងឺរលាកតម្រងនោមដែលបណ្តាលមកពីជំងឺទឹកនោមប្រៃ ជំងឺឆ្អួតជ្រូកធ្ងន់ធ្ងរ ជំងឺឈាមក្រកក Aនិង Bធ្ងន់ធ្ងរ។សូមអានឯកសារបណ្ណសន្យារ៉ាប់រងសម្រាប់និយមន័យ និង ករណីមិនធានា ចំពោះករណីនីមួយៗ។
- **ផលវិបាកនៃការមានគភ៌៖** សុករបើកពីស្បូន រលាកថ្លើមដោយសារខ្លាញ់ស្រួចស្រាវនិងធ្ងន់ធ្ងរលើស្ត្រីមានគភ៌ ស្ទះសរសៃរឈាមដោយសារទឹកភ្លោះ មហារីកកោសិកាសុក និង កូនពងកាច ឈាមកកដេរដាសក្នុងសរសៃឈាម កូនក្រៅស្បូន សុកភ្ជាប់ចូលជ្រៅដល់សាច់ដុំស្បូន រឺ ជ្រៅហួសសាច់ដុំស្បូនទៅដល់សរីរាង្គជិតខាង ការហូរឈាមក្រោយសំរាលដែលតម្រូវឱ្យវះកាត់ស្បូនចេញ បំរុងក្រឡាភ្លើង រឺ ក្រឡាភ្លើង និងទារកស្លាប់កើត។ សូមអានឯកសារបណ្ណសន្យារ៉ាប់រងសម្រាប់និយមន័យ និង ករណីមិនធានា ចំពោះករណីនីមួយៗ។

**(*) បំណែងចែកក្រុមមុខរបរ៖**

- ក្រុមមុខរបរ 1 សំដៅដល់៖
  - តួនាទីការិយាល័យ តួនាទីការងារដែលមិនពាក់ព័ន្ធនឹងការប្រើកម្លាំងកាយសម្បទាដែលមិនប្រឈមនឹងគ្រោះថ្នាក់ ឬហានិភ័យដល់សុខភាព
- ក្រុមមុខរបរ 2 សំដៅដល់៖
  - តួនាទីដែលស្រដៀងនឹងក្រុម1 ប៉ុន្តែមានការធ្វើដំណើរ ការចុះស្រាវជ្រាវដល់កន្លែង ឬ អាចប្រឈមនឹងគ្រោះថ្នាក់ ឬហានិភ័យដល់សុខភាពតិចតួច
  - តួនាទីបុគ្គលិកមានជំនាញ ដែលមានពាក់ព័ន្ធនឹងការប្រើកម្លាំងកាយសម្បទាកម្រិតមធ្យម និង បុគ្គលិកពាក់កណ្តាលជំនាញដែលមានពាក់ព័ន្ធនឹងការប្រើកម្លាំងកាយសម្បទាកម្រិតតិច
- ក្រុមមុខរបរ 3 សំដៅដល់៖
  - តួនាទីដែលអាចប្រឈមគ្រោះថ្នាក់ ឬ ហានិភ័យសុខភាពកម្រិតមធ្យម
  - តួនាទីបុគ្គលិកមានជំនាញ ដែលមានពាក់ព័ន្ធនឹងការប្រើកម្លាំងកាយសម្បទាជាចម្បង និង បុគ្គលិកពាក់កណ្តាលជំនាញដែលមានពាក់ពន្ធនឹងការប្រើកម្លាំងកាយសម្បទាកម្រិតមធ្យម
- ក្រុម 4 សំដៅដល់៖
  - តួនាទីដែលប្រឈមនឹងគ្រោះថ្នាក់ ឬ ហានិភ័យដល់សុខភាព ឬ ការប្រើកម្លាំងកាយសម្បទាកម្រិតខ្លាំង
  - តួនាទីពាក់កណ្តាលជំនាញដែលមានលក្ខណៈតម្រូវឲ្យប្រើកម្លាំងកាយសម្បទា និង តួនាទីមិនមានជំនាញណាមួយហើយអាចមានការប្រើកម្លាំងកាយសម្បទា និងអាចប្រឈមឧបត្តិហេតុ។

**3. តើខ្ញុំត្រូវបង់បុព្វលាភធានារ៉ាប់រងចំនួនប៉ុន្មាន?**

- បុព្វលាភធានារ៉ាប់រងនឹងត្រូវបានគណនាផ្អែកទៅលើអាយុ ភេទ ភាពញឹកញាប់នៃការបង់បុព្វលាភធានារ៉ាប់រង ទឹកប្រាក់ត្រូវបានធានារ៉ាប់រង និង អត្ថប្រយោជន៍ដែលអតិថិជនដែលអតិថិជនបានជ្រើសរើស។
- បុព្វលាភធានារ៉ាប់រងនឹងត្រូវបានធានាក្នុងរយៈពេល 5 (ប្រាំ) ឆ្នាំ នៃរយៈពេលកំណត់នៃបណ្ណសន្យារ៉ាប់រង។ បុព្វលាភធានារ៉ាប់រងនឹងប្រែប្រួលរាល់ពេលធ្វើការបន្តសុពលភាពបណ្ណសន្យារ៉ាប់រង ដែលបុព្វលាភធានា

រ៉ាប់រងថ្មីនោះនឹងផ្អែកទៅលើ អាយុនៅពេលធ្វើការបន្តសុពលភាពបណ្ណសន្យារ៉ាប់រង ទឹកប្រាក់ត្រូវបានធានារ៉ាប់រង និងការផ្លាស់ប្តូរនៃអត្ថប្រយោជន៍ធានារ៉ាប់រងដែលអតិថិជនបានជ្រើសរើស។

**4. តើផលិតផល PRUថែទាំ មានភាពញឹកញាប់នៃការបង់បុព្វលាភធានារ៉ាប់រងប៉ុន្មានជម្រើស? តើបុព្វលាភធានារ៉ាប់រងមានការធានាដែរឬទេ?**

មាន 4 ជម្រើសនៃការបង់បុព្វលាភធានារ៉ាប់រង៖ ការទូទាត់ប្រចាំឆ្នាំ ប្រចាំឆមាស ប្រចាំត្រីមាស និងប្រចាំខែ។ បុព្វលាភធានារ៉ាប់រងនឹងត្រូវបានធានាក្នុងរយៈពេលកំណត់នៃបណ្ណសន្យារ៉ាប់រង ប៉ុន្តែបុព្វលាភធានារ៉ាប់រងនឹងមិនត្រូវបានធានានិងងប្រែប្រួលនៅពេលធ្វើការបន្តសុពលភាពបណ្ណសន្យារ៉ាប់រង។

**5. តើ ខ និងលក្ខខណ្ឌអ្វីខ្លះ ដែលខ្ញុំគួរយល់ដឹងទាក់ទងនឹងផលិតផល?**

**សារៈសំខាន់នៃការផ្តល់ព័ត៌មានរបស់អតិថិជន -** លោកអ្នកត្រូវមានសុខភាពល្អនៅពេលទិញផលិតផល និង បំពេញតែព័ត៌មានដែលពិតប្រាកដ។ លោកអ្នកត្រូវបង្ហាញការពិតដែលអ្នកយល់ថាមានពាក់ព័ន្ធនឹងការចេញបណ្ណសន្យារ៉ាប់រងរបស់យើងខ្ញុំ ហើយចៀសវាងការភាន់បន្លំផ្សេងៗ។ លោកអ្នកមានកាតព្វកិច្ចក្នុងការផ្តល់ព័ត៌មានរហូតដល់ការចេញបណ្ណសន្យារ៉ាប់រង។

**រយៈពេលពិចារណា -** មាន។ ប្រសិនបើអ្នកធ្វើការសម្រេចចិត្តថាមិនបន្តបណ្ណសន្យារ៉ាប់រងទៀតទេ នោះអ្នកអាចធ្វើការលុបចោលបណ្ណសន្យារ៉ាប់រងវិញ ដោយជូនដំណឹងមកក្រុមហ៊ុន ក្នុងរយៈពេល 21 (ម្ភៃមួយ) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការចេញវិញ្ញាបនបត្រធានារ៉ាប់រងអាយុជីវិត (តទៅហៅកាត់ថា “រយៈពេលសាកល្បង/រយៈពេលពិចារណា”)។ ក្នុងករណីដែលបណ្ណសន្យារ៉ាប់រងត្រូវបានលុបចោល ក្នុងរយៈពេលសាកល្បងនេះ ក្រុមហ៊ុននឹងធ្វើការបង្វិលប្រាក់ជូនម្ចាស់បណ្ណសន្យារ៉ាប់រងវិញ ដូចខាងក្រោម៖

- បុព្វលាភធានារ៉ាប់រងសរុបដែលបានបង់ ដោយដកយកមកវិញនូវ
- ថ្លៃពិនិត្យសុខភាពណាមួយដែលបានចំណាយ (ប្រសិនបើមាន) និង/ឬ
- ចំនួនទឹកប្រាក់ណាមួយដែលនៅជំពាក់ក្រុមហ៊ុន (ប្រសិនបើមាន)។

បន្ទាប់ពីការបង្វិលបុព្វលាភធានារ៉ាប់រងឲ្យវិញរួចរាល់ បណ្ណសន្យារ៉ាប់រងត្រូវអស់សុពលភាពភ្លាម ដោយគិតចាប់ពីកាលបរិច្ឆេទមានសុពលភាពនៃបណ្ណសន្យារ៉ាប់រង។

**ការទាមទារសំណង** – សូមយោងលើឯកសារបណ្ណសន្យារ៉ាប់រង ឬ កម្រងសំណួរ-ចម្លើយសំខាន់ៗ ដើម្បីស្វែងយល់បន្ថែមទៅលើនីតិវិធីនៃការទាមទារសំណង។

**រយៈពេលរង់ចាំ** – រយៈពេលរង់ចាំមានដូចខាងក្រោម៖

- ជំងឺធ្ងន់ធ្ងរ ជំងឺធ្ងន់ធ្ងរកើតឡើងលើកុមារ អត្ថប្រយោជន៍បន្ថែមលើជំងឺមហារីក (តាមភេទ) ផលវិបាកនៃជំងឺទឹកនោមផ្អែម៖ 90 (កៅសិប) ថ្ងៃ។
- ផលវិបាកនៃការមានគភ៌ ៖ 300 (បីរយ) ថ្ងៃ។

**រយៈពេលរស់រានមានជីវិត (Survival Period)** – 14 (ដប់បួន) ថ្ងៃរាប់ចាប់ពីកាលបរិច្ឆេទដំបូង ដែលអ្នកត្រូវបានធានារ៉ាប់រងបានធ្វើរោគវិនិច្ឆ័យរកឃើញមានជំងឺឬស្ថានភាពដូចខាងក្រោម។ ក្រុមហ៊ុនសូមបដិសេធក្នុងការទូទាត់អត្ថប្រយោជន៍ក្រោមផលិតផលធានារ៉ាប់រងបន្ថែម ប្រសិនបើការទាមទារសំណងត្រូវបានកើតឡើងដោយផ្ទាល់ ឬដោយប្រយោលចំពោះអ្នកត្រូវបានធានារ៉ាប់រងដូចខាងក្រោម៖

- អ្នកត្រូវបានធានារ៉ាប់រងទទួលមរណភាពក្នុងអំឡុងពេល 14 (ដប់បួន) ថ្ងៃរាប់ចាប់ពីកាលបរិច្ឆេទដំបូងដែលអ្នកត្រូវបានធានារ៉ាប់រងបានធ្វើរោគវិនិច្ឆ័យថាមានជំងឺធ្ងន់ធ្ងរ លើកលែងតែជំងឺមហារីកដំណាក់កាលធ្ងន់ធ្ងរ។

- អ្នកត្រូវបានធានារ៉ាប់រងទទួលមរណភាពក្នុងអំឡុងពេល 14 (ដប់បួន) ថ្ងៃរាប់ចាប់ពីកាលបរិច្ឆេទដំបូងដែលអ្នកត្រូវបានធានារ៉ាប់រងបានធ្វើរោគវិនិច្ឆ័យថាមានជំងឺធ្ងន់ធ្ងរកើតឡើងលើកុមារ។
- អ្នកត្រូវបានធានារ៉ាប់រងទទួលមរណភាពក្នុងរយៈពេល 14 (ដប់បួន) ថ្ងៃរាប់ចាប់ពីកាលបរិច្ឆេទដំបូងដែលអ្នកត្រូវបានធានារ៉ាប់រងបានធ្វើរោគវិនិច្ឆ័យថាមានផលវិបាកនៃជំងឺទឹកនោមផ្អែម។

**ការវាយតម្លៃបណ្ណសន្យារ៉ាប់រង** – បំពេញលើសន្ទស្សន៍ម៉ាសរាងកាយ (កំពស់ និងទំងន់) និង ធ្វើសេចក្តីប្រកាសលើសុខភាពឬឆ្លើយសំណួរលើសុខភាព ចំនួន 2 (ពីរ) តែប៉ុណ្ណោះ។ ក្នុងករណីអត្ថប្រយោជន៍ផលវិបាកនៃការមានគភ៌ត្រូវបានជ្រើសរើស នោះអតិថិជននឹងតម្រូវឲ្យធ្វើសេចក្តីប្រកាសលើសុខភាពឬឆ្លើយសំណួរលើសុខភាពចំនួន 1 (មួយ) ទៀត។

**ការផ្ទៀងផ្ទាត់អត្តសញ្ញាណ** - នៅពេលលោកអ្នកផ្តល់រូបភាពនៃអត្តសញ្ញាណបណ្ណ លោកអ្នកត្រូវប្រាកដថារូបភាពដែលបានផ្តល់នឹងបង្ហាញព័ត៌មានលម្អិតរបស់អ្នកអោយបានច្បាស់លាស់។ បណ្ណសន្យារ៉ាប់រងរបស់អ្នកអាចនឹងត្រូវបានបដិសេធ ប្រសិនបើយើងមិនអាចផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់អ្នកបានយ៉ាងពេញលេញតាមរយៈឯកសារដែលបានផ្តល់ជូននោះទេ។

**ការបន្តសុពលភាពកិច្ចសន្យាធានារ៉ាប់រង** - ផលិតផលនេះមានរយៈពេលកំណត់នៃបណ្ណសន្យារ៉ាប់រងចំនួន 5ឆ្នាំ និងអាចធ្វើការបន្តសុពលភាពបណ្ណសន្យារ៉ាប់រង អាស្រ័យទៅតាមលក្ខខណ្ឌខាងក្រោម៖

- អ្នកត្រូវបានធានារ៉ាប់រងត្រូវមានអាយុថ្ងៃខួបកំណើតចុងក្រោយតិចជាង 66 (ហុកសិបប្រាំមួយ) ឆ្នាំនៅពេលធ្វើការបន្តសុពលភាពបណ្ណសន្យារ៉ាប់រង
- ម្ចាស់បណ្ណសន្យារ៉ាប់រងត្រូវទូទាត់បុព្វលាភធានារ៉ាប់រងបន្ថែមទៅតាមអាយុរបស់អ្នកត្រូវបានធានារ៉ាប់រងនៅពេលធ្វើការបន្តសុពលភាពបណ្ណសន្យារ៉ាប់រង និង
- បណ្ណសន្យារ៉ាប់រងមិនទាន់ត្រូវបានបញ្ចប់សុពលភាពក្រោយពីមានការទាមទារសំណង
- ការបន្តសុពលភាពលើបណ្ណសន្យារ៉ាប់រងនេះនឹងត្រូវអនុវត្តដោយយោងតាមគោលនយោបាយការណ៍ស្តីពីការចេញបណ្ណសន្យារ៉ាប់រងរបស់ក្រុមហ៊ុន។

ការបន្តសុពលភាពបណ្ណសន្យារ៉ាប់រងមិនត្រូវបានធានានោះទេ និង ត្រូវអនុវត្តដោយយោងតាមគោលការណ៍ស្តីពីការចេញបណ្ណសន្យារ៉ាប់រងរបស់ក្រុមហ៊ុន។ ក្រុមហ៊ុនរក្សាសិទ្ធិក្នុងការការមិនបន្តសុពលភាពបណ្ណសន្យារ៉ាប់រងសម្រាប់ផលិតផលធានារ៉ាប់រងនេះ។

*សម្គាល់: ចំនុចដែលលើកឡើងខាងលើអាចមានច្រើនទៀត សូមអានឯកសារបណ្ណសន្យារ៉ាប់រង ដើម្បីស្វែងយល់បន្ថែមពី ខ និងលក្ខខណ្ឌដែលស្ថិតក្រោមបណ្ណសន្យារ៉ាប់រងនេះ។*

## 6. តើករណីមិនធានារបស់ផលិតផល PRUថែទាំ និង ផលិតផលធានារ៉ាប់រងបន្ថែម PRUការពារជំងឺធ្ងន់ធ្ងរ មានអ្វីខ្លះ?

### 6.1. ករណីមិនធានារបស់ផលិតផលធានារ៉ាប់រង PRUថែទាំ

ក្រុមហ៊ុននឹងបដិសេធក្នុងការទូទាត់អត្ថប្រយោជន៍ដូចដែលបានរៀបរាប់ខាងលើ ប្រសិនបើការទាមទារសំណររបស់អ្នកត្រូវបានធានារ៉ាប់រងត្រូវបានកើតឡើងដូចលក្ខខណ្ឌណាមួយខាងក្រោម៖

- ការធ្វើអត្តឃាត ឬ ការប៉ុនប៉ងធ្វើអត្តឃាត ឬ ធ្វើឲ្យរបួសខ្លួនឯង ទោះបីជាស្ថិតក្នុងស្ថានភាពផ្លូវចិត្តប្រក្រតី ឬមិនប្រក្រតីក៏ដោយ។

- ការប្រព្រឹត្ត ឬ ការប៉ុនប៉ងប្រព្រឹត្តនូវបទល្មើសព្រហ្មទណ្ឌ។ ក្នុងករណីបទល្មើសព្រហ្មទណ្ឌត្រូវបានប្រព្រឹត្តដោយអ្នកទទួលផលម្នាក់ ឬ ច្រើននាក់ នោះមានតែអ្នកទទួលផលដែលមិនពាក់ព័ន្ធនឹងបទល្មើសព្រហ្មទណ្ឌប៉ុណ្ណោះ ដែលនៅមានសិទ្ធិក្នុងការទទួលអត្ថប្រយោជន៍។
- ការប្រើគ្រឿងញៀន ឬ ថ្នាំសប្បាយ ការសេពគ្រឿងស្រវឹងហួសកម្រិត ឬ បើកបរយានជំនិះក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង ដូចមានចែងនៅក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមាន។
- ស្ថានភាព ឬជំងឺមានពីមុនស្រាប់ ដូចដែលបានចែងក្នុងបណ្ណសន្យារ៉ាប់រងរបស់ផលិតផលនេះ។

**6.2. ករណីមិនធានារបស់ផលិតផលធានារ៉ាប់រងបន្ថែម PRUការពារជំងឺធ្ងន់ធ្ងរ**

ក្រុមហ៊ុននឹងបដិសេធក្នុងការទូទាត់អត្ថប្រយោជន៍ដូចដែលបានរៀបរាប់ខាងលើ ប្រសិនបើការទាមទារសំណងត្រូវបានកើតឡើងដោយផ្ទាល់ ឬ ប្រយោលចំពោះអ្នកត្រូវបានធានារ៉ាប់រងដូចខាងក្រោម៖

- ស្ថានភាព ឬជំងឺមានពីមុនស្រាប់ ដូចដែលបានចែងក្នុងបណ្ណសន្យារ៉ាប់រងរបស់ផលិតផលនេះ។
- ជំងឺឬស្ថានភាពណាមួយដែលមានវត្តមាន ឬត្រូវបានធ្វើរោគវិនិច្ឆ័យក្នុងរយៈពេលរង់ចាំ។
- ការធ្វើអត្តឃាត ការប៉ុនប៉ងធ្វើអត្តឃាត ឬ ការធ្វើឲ្យរបួសខ្លួនឯង ទោះបីជាស្ថិតក្នុងស្ថានភាពផ្លូវចិត្តប្រក្រតី ឬ មិនប្រក្រតីក៏ដោយ។
- ការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ឬ ការប៉ុនប៉ងប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ឬ ការបង្កឲ្យមានការវាយប្រហារ ឬបទ ល្មើសព្រហ្មទណ្ឌ ដោយម្ចាស់បណ្ណសន្យារ៉ាប់រង អ្នកត្រូវបានធានារ៉ាប់រង ឬ អ្នកទទួលផល។
- ស្ថិតក្រោមឥទ្ធិពលនៃការប្រើប្រាស់គ្រឿងញៀន ឬគ្រឿងស្រវឹង។
- ការធ្វើរោគវិនិច្ឆ័យរកឃើញជំងឺ ឬស្ថានភាពណាមួយ ដោយសារភាពមិនប្រក្រតីពីកំណើតមិនថាដោយផ្ទាល់ ឬដោយប្រយោលក៏ដោយ។
- អ្នកត្រូវបានធានារ៉ាប់រងទទួលមរណភាពក្នុងអំឡុងពេលរយៈពេលរស់រានមានជីវិតដូចដែលបានចែងខាងលើ។

ប្រសិនបើអត្ថប្រយោជន៍លើ**ការវះកាត់ស្តារឡើងវិញ ឬការផ្សាំនៃស្បែក** ត្រូវបានជ្រើសរើស នោះករណីមិនធានាខាងក្រោមនេះក៏នឹងត្រូវបានអនុវត្តបន្ថែមពីលើករណីមិនធានាខាងលើផងដែរ។ ក្រុមហ៊ុននឹងបដិសេធក្នុងការទូទាត់អត្ថប្រយោជន៍ដូចដែលបានរៀបរាប់ខាងលើ ប្រសិនបើការទាមទារសំណងត្រូវបាន កើត ឡើងចំពោះអ្នកត្រូវបានធានារ៉ាប់រងដូចខាងក្រោម៖

- ការព្យាបាលសម្រាប់ជំងឺ ឬរបួសបណ្តាលមកពីអ្នកត្រូវបានធានារ៉ាប់រងចូលរួមនៅក្នុងសកម្មភាពដែលងាយមានគ្រោះថ្នាក់ ឬសកម្មភាពកីឡាសម្រាប់ការកំសាន្តឬអាជីព ឬ សកម្មភាពឬកីឡាផ្សេងៗដែលអាចរកប្រាក់ចំណូលពីសកម្មភាពទាំងនោះ។
- ការងើបបះបោរប្រឆាំងរដ្ឋាភិបាល កូដកម្ម ភេរវកម្ម ការរំលោភឬការប៉ុនប៉ងរំលោភច្បាប់ ការទប់ទល់ប្រឆាំងទៅនឹងការចាប់ខ្លួនឬការដាក់ពន្ធនាគារណាមួយ។
- ផលវិបាកដែលកើតឡើងដោយផ្ទាល់ឬដោយប្រយោលពី ការធ្លាក់នុយក្លេអ៊ែរ វិទ្យុសកម្ម សមាសភាពនុយក្លេអ៊ែរ សម្ភារៈឬកាកសំណល់នុយក្លេអ៊ែរ និង ហានិភ័យពាក់ព័ន្ធនឹងសង្គ្រាមផ្សេងៗទៀត។

**7. តើខ្ញុំអាចបញ្ចប់បណ្ណសន្យារ៉ាប់រងរបស់ខ្ញុំបានដែរឬទេ?**

លោកអ្នកអាចបញ្ចប់បណ្ណសន្យារ៉ាប់រងបាន ប៉ុន្តែនឹងពុំមានការផ្តល់ជូនបុព្វលាភធានារ៉ាប់រងដែលបានទូទាត់រួចវិញនោះទេ បន្ទាប់ពីផុតរយៈពេលពិចារណា 21 ថ្ងៃ។

**8. តើបណ្ណសន្យារ៉ាប់រងនឹងត្រូវលុបចោលយ៉ាងដូចម្តេច?**

| |
|---|
| បណ្ណសន្យារ៉ាប់រងនឹងត្រូវបញ្ចប់ដោយស្វ័យប្រវត្តិ នៅកាលដែលហេតុការណ៍ណាមួយខាងក្រោមកើតឡើង៖<br>- ករណីមរណភាព ឬ ករណីពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍របស់អ្នកត្រូវបានធានារ៉ាប់រង **ឬ**<br>- ករណីដែលបានទូទាត់សំណងទៅតាមអត្ថប្រយោជន៍នៃបណ្ណសន្យារ៉ាប់រងជូនរួចរាល់ទៅតាមលក្ខខណ្ឌក្រោមបណ្ណសន្យារ៉ាប់រងនេះ **ឬ**<br>- បន្ទាប់ពីទទួលបានសំណើរបស់ម្ចាស់បណ្ណសន្យារ៉ាប់រង ក្នុងការបោះបង់បណ្ណសន្យារ៉ាប់រង **ឬ**<br>- ដល់ថ្ងៃផុតកំណត់នៃរយៈពេលកំណត់នៃបណ្ណសន្យារ៉ាប់រង **ឬ**<br>- អ្នកត្រូវបានធានារ៉ាប់រងបានដល់អាយុផុតសុពលភាពធានារ៉ាប់រង (អាយុថ្ងៃខួបកំណើតចុងក្រោយ) **ឬ**<br>- ក្រុមហ៊ុនបញ្ចប់គម្រោងមូលដ្ឋាន ស្របតាម ខ និងលក្ខខណ្ឌដែលមានចែងក្នុងនេះ **ឬ**<br>- មានស្ថានភាពផ្សេងទៀត ដែលកំណត់ដោយច្បាប់ស្តីពីការធានារ៉ាប់រងដែលមានស្រាប់ **ឬ**<br>- ក្រុមហ៊ុនរក្សាសិទ្ធិក្នុងការធ្វើការបញ្ចប់បណ្ណសន្យារ៉ាប់រង ឬមិនផ្តល់ជូនសំណង ក្នុងករណីម្ចាស់សន្យារ៉ាប់រង ឬអ្នកត្រូវបានធានារ៉ាប់រងនៃបណ្ណសន្យារ៉ាប់រងនេះមិនបានផ្តល់ជូនព័ត៌មានពិតសំខាន់ៗសម្រាប់ការវិភាគកម្រិតហានិភ័យមុនការចេញបណ្ណសន្យារ៉ាប់រង ឬការផ្តល់ជូនផ្សេងទៀតនៃកញ្ចប់ផលិតផលនេះ។ |
| **9. តើខ្ញុំអាចផ្លាស់ប្តូរព័ត៌មានរបស់ខ្ញុំបានយ៉ាងដូចម្តេច?** |
| លោកអ្នកអាចផ្លាស់ប្តូរ និងធ្វើបច្ចុប្បន្នភាពអាសយដ្ឋាន និង ព័ត៌មានទំនាក់ទំនងរបស់អ្នក នៅក្នុងទំព័រ "គណនីរបស់ខ្ញុំ -> ប្រវត្តិរូបរបស់ខ្ញុំ" នៅក្នុងកម្មវិធីទូរស័ព្ទដៃរបស់ក្រុមហ៊ុនព្រូដិនសល ឈ្មោះថា Pulse។ |
| **10. តើខ្ញុំអាចទទួលបានព័ត៌មានបន្ថែមតាមរយៈណា?** |
| សម្រាប់ជំនួយលើសេវាកម្មនិងសំណួរផ្សេងៗ លោកអ្នកអាចទាក់ទងទៅកាន់ផ្នែកសេវាកម្មអតិថិជនដូចខាងក្រោម៖<br>- លេខទូរស័ព្ទទំនាក់ទំនង ៖ 023 964 222 ឬ 1800 21 22 23 (ឥតគិតថ្លៃ)<br>- អ៊ីម៉ែល ៖ info@prudential.com.kh<br>- គេហទំព័រហ្វេសប៊ុក ៖ Prudential Cambodia<br>គេហទំព័រ ៖ www.prudential.com.kh/ |
| **កំណត់សម្គាល់សំខាន់៖**<br><br>នេះគឺជាផលិតផលសម្រាប់ផ្តល់ការការពារ ហើយមិនរាប់បញ្ចូលការសន្សំ ឬការវិនិយោគណាមួយឡើយ។ ការធានារ៉ាប់រងនេះនឹងបំពេញសេចក្តីត្រូវការរបស់អ្នកបានយ៉ាងប្រសើរ។ លោកអ្នកគួរអាននិងស្វែងយល់ពីឯកសារបណ្ណសន្យារ៉ាប់រង ឬ ទាក់ទងមកកាន់ក្រុមហ៊ុនដោយផ្ទាល់សម្រាប់ព័ត៌មានបន្ថែម។ |